# សេចក្តីប្រកាសព័ត៌មានរបស់ ម.ស.ម.ក

## សកម្មជនបរិស្ថានបីរូបត្រូវបានចាប់ខ្លួន

**កាលបរិច្ឆេទនៃហេតុការណ៍៖** ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០
**ប្រភេទអ្នកការពារសិទ្ធិមនុស្ស៖** សកម្មជនបរិស្ថាន
**ទីកន្លែង៖** រាជធានីភ្នំពេញ
**ប្រភេទនៃការគំរាមកំហែង ៖** សេរីភាពបញ្ចេញមតិ

នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០នេះ លោក ថុន រដ្ឋា ដែលជាសកម្មជនបរិស្ថាន និងជាសមាជិកមាតាធម្មជាតិកម្ពុជាត្រូវបានចាប់ខ្លួននៅផ្ទះជួលរបស់លោកដែលស្ថិតក្នុងខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ មានអាជ្ញាធរជាច្រើននាក់ ដែលរួមមានសន្តិសុខ និងនគរបាលប្រមាណ២៥នាក់ បានឡោមព័ទ្ធផ្ទះរបស់លោកអស់រយៈពេលប្រមាណពីរម៉ោងមុនពេលនាំខ្លួនចេញទៅនៅម៉ោង ១២:៤០ នាទីរសៀល។ អ្នកឃ្លាំមើលសិទ្ធិមនុស្សត្រូវបានអាជ្ញាធររារាំងក្នុងការចូលទៅជិតផ្ទះរបស់លោក រដ្ឋា ខណៈពេលដែលនគរបាលចាប់ខ្លួនរូបលោក។ អាជ្ញាធរបានចាក់សោរផ្ទះ ហើយបិទលិខិតមួយច្បាប់ជាប់នឹងទ្វារផ្ទះរបស់លោក រដ្ឋា ដែលបង្ហាញថាប្រតិបត្តិការនេះដឹកនាំដោយ ស្នងការរងរាជធានីភ្នំពេញ សហការជាមួយ អនុប្រធានមន្ទីរព័ត៌មាន ព្រះរាជអាជ្ញារង និងអាជ្ញាធរពាក់ព័ន្ធផ្សេងទៀត។ ក្នុងលិខិតនោះបញ្ជាក់ថា វិធានការត្រូវបានធ្វើឡើងដោយសារតែលោក រដ្ឋា បាន «*ផ្សាយព័ត៌មានដោយពុំមានច្បាប់អនុញ្ញាត*»។ ទោះបីយ៉ាងណានៅមិនទាន់ដឹងថាព័ត៌មានអ្វីដែលត្រូវបានផ្សព្វផ្សាយ ឬច្បាប់ណាដែលតម្រូវឱ្យសុំការអនុញ្ញាតចំពោះការផ្សព្វផ្សាយនោះនៅឡើយទេ។

សកម្មជនមាតាធម្មជាតិមួយរូបទៀតគឺកញ្ញា ឡុង គន្ធា ជាជនទីពីរត្រូវបានចាប់ខ្លួននៅថ្ងៃនេះ។ មានការរាយការណ៍ថា អាជ្ញាធរបានតាមដានគាត់ខណៈពេលដែលកញ្ញាគ្រោងដើរពីវត្តភ្នំសំដៅទៅផ្ទះរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នាពេលព្រឹកនេះ។ កញ្ញាមានបំណងស្នើសុំជួបជាមួយនាយករដ្ឋ

មន្ត្រីដើម្បីបង្ហាញពីក្ដីកង្វល់របស់នាងពាក់ព័ន្ធនឹងបញ្ហាបរិស្ថានមួយចំនួន រួមមានការអភិវឌ្ឍបឹងតាមោក ដែលជាបឹងចុងក្រោយបង្អស់ក្នុងរាជធានីភ្នំពេញដែលនៅសេសសល់ ដែលនឹងប៉ះពាល់ពពួកសត្វស្លាប និងបំផ្លាញជីវៈចម្រុះ ហើយវាអាចបណ្ដាលឱ្យមានគ្រោះទឹកជំនន់ក្នុងរាជធានីភ្នំពេញ។

កញ្ញា ភួន កែវរស្មី ជាសកម្មជនមាតាធម្មជាតិទីបីដែលត្រូវបានចាប់ខ្លួនជាមួយកញ្ញា ឡុង គន្ធា នាព្រឹកនេះ ប៉ុន្តែមូលហេតុនៃការចាប់ខ្លួននៅមិនទាន់ដឹងនៅឡើយ។ មានការរាយការណ៍ថា គន្ធា និង រស្មី ត្រូវឃាត់ខ្លួនដើម្បីសួរចម្លើយនៅអធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ ហើយនគរបាលបានបញ្ជូនពួកគេចេញនៅម៉ោងប្រមាណ ៦ល្ងាចទៅកន្លែងផ្សេងទៀត។

អ្នកនាំពាក្យនៃស្នងការនគរបាលរាជធានីភ្នំពេញក៏បានបញ្ជាក់អំពីការចាប់ខ្លួននៃសកម្មជនទាំងបីរូបនោះផងដែរ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក សួន យុធ្យា នាយកផ្នែកតស៊ូមតិ នៃ ម.ស.ម.ក តាមរយៈទូរស័ព្ទ៖ +៨៥៥ (០) ៨៨ ៨១ ៤២ ៧៨៣ ឬអ៊ីម៉ែល ៖ yuthyia@cchrcambodia.org។